**Japan International Cooperation Center**
**JDS Project Office in Cambodia**
Unit No. 306, AURA Condominium Building,
#87, Street 63, Sangkat Beong Rang, Daun Penh, Phnom Penh, Cambodia
Tel: (855-23) 217 944 | Mobile: (855-12) 681 611
URL: http://sv2.jice.org/jds

August 16, 2022

H.E. Hem Vanndy
Secretary of State,
Ministry of Economy and Finance

RE: **Request to promote applications for JDS scholarship program from your organization**

We, Japan International Cooperation Center **(JICE)** as an agent of Ministry of Education, Youth and Sport **(MoEYS)** would like to express our sincere gratitude for your kind attention to **The Project for Human Resource Development Scholarship Program by Japanese Grant Aid (JDS)** funded by the Government of Japan, which **is targeted at highly capable young government officials and others** who are expected to engage in formulating and implementing social and economic development plans and become leaders in Cambodia by studying in **Master's program (in English)** in Japan.

**The recruitment of this year (JDS2022) will be officially opened on August 22, 2022.**
**To promote applications from your organization, we would like to ask for your cooperation today in the following points.**

- **To disseminate and share JDS information in your Ministry / Institution**
- **To encourage your young officials to participate in our promotion seminars**
  For details on the seminar schedule, please check JDS website (**https://jds-scholarship.org/**)
- **To encourage your young officials to apply for JDS scholarship program**
- **To put up a JDS poster in your organization**

We appreciate your attention, cooperation, and consideration in this matter. We are enclosing information on JDS scholarship program of this year for your perusal, and if you have any question, feel free contact us.

Sincerely yours,

森下泰王

MORISHITA Taishi
Country Officer
JICE JDS Cambodia Project Office

JAPAN INTERNATIONAL COOPERATION CENTER JICE PROJECT OFFICE Cambodia

**Enclosed:**
- A letter issued by Ministry of Education, Youth and Sport
- Poster of JDS scholarship
- Application Guidelines (AG)

Mr. Bin Kakda , Director , Personnel Department

Ms. En Dara , Deputy Director , Personnel Department, incharge of Training Management and HR Development

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៤៥ **អយក.**សភ៧

# សេចក្តីជូនដំណឹង
## ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតក្រោមគម្រោងអាហារូបករណ៍របស់ប្រទេសជប៉ុនសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជា (JDS) សម្រាប់ឆ្នាំ២០២២

**យោង៖** លិខិតចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICE-JDS) ប្រចាំកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់ **មន្ត្រីរាជការ** ទាំងពីរភេទ ជ្រាបថា៖ កម្មវិធីអាហារូបករណ៍ជប៉ុន ក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុន សម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា **(JDS)** នឹងទទួលបណ្តុះបណ្តាលនិស្សិតអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (Master Degree) រយៈពេល ០២ឆ្នាំ ចំនួនអតិបរមា **២៤នាក់** និងថ្នាក់បណ្ឌិត (Ph.D Degree) រយៈពេល ០៣ឆ្នាំ ចំនួនអតិបរមា **០២នាក់** នៅប្រទេសជប៉ុន ក្នុងឆ្នាំ២០២៣។

មធ្យោបាយធ្វើដំណើរទៅមក កម្ពុជា/ជប៉ុន/កម្ពុជា ថ្លៃសិក្សា ប្រាក់អាហារូបករណ៍ ជាបន្ទុករបស់រាជរដ្ឋាភិបាលជប៉ុន។

**I. លក្ខខណ្ឌនៃការជ្រើសរើស**

**១. ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (Master)**

**បេក្ខជនទាំងពីរភេទត្រូវ៖**

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្របរិញ្ញាបត្រ (Bachelor's Degree)
- មានអាយុចន្លោះពី២២-៣៩ឆ្នាំ គិតដល់**ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣**
- មានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ ព្រោះការសិក្សាយកភាសាអង់គ្លេសជាយាន
- មានបទពិសោធន៍ការងារយ៉ាងតិច ០២ឆ្នាំ **ជាបុគ្គលិករដ្ឋ**ដែលធ្វើការពេញម៉ោងតាមស្ថាប័នពាក់ព័ន្ធ (ចំពោះបុគ្គលិកជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាតទេ)
- មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា។

**<u>កំណត់ចំណាំ</u>**

បេក្ខជនដែលមិនមែនជាក្រុមគោលដៅរបស់គម្រោងអាហារូបករណ៍ JDS មានដូចជា៖

- គ្រូបង្រៀន (បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ សាកលវិទ្យាល័យ PTTC / RTTC / TEC /NIE / NISE / NIPSE) និងមន្ត្រីបម្រើការងារនៅតាមវិទ្យាស្ថានបណ្តុះបណ្តាលក្រោមក្រសួង។
- បុគ្គលិកដែលបម្រើការងារនៅមន្ទីរពេទ្យ មន្ត្រីប៉ូលីស និងមន្ត្រីផ្នែកពន្លត់អគ្គិសភ័យ។

☛សម្រាប់ព័ត៌មានលម្អិតសូមពិនិត្យមើលឯកសារអង្គភាពគោលដៅដែលមានភ្ជាប់ជូន។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

២.ថ្នាក់បណ្ឌិត (Doctorate)

**បេក្ខជនទាំងពីរភេទត្រូវ៖**

- មានសញ្ជាតិខ្មែរ
- មន្ត្រីដែលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (Master) ក្រោមកម្មវិធីអាហារូបករណ៍ JDS
- មានអាយុក្រោម **៤៥ឆ្នាំ** គិតដល់**ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣**
- មានបទពិសោធន៍ការងារយ៉ាងតិច **២ឆ្នាំ** បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមកម្មវិធីអាហារូបករណ៍ JDS
- ត្រូវមានអត្ថបទត្រួតពិនិត្យរួមគ្នា យ៉ាងហោចណាស់មួយអត្ថបទ ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រដែលទទួលស្គាល់ជាអន្តរជាតិ ឬមានផែនការច្បាស់លាស់ក្នុងការបោះពុម្ពផ្សាយក្នុងកំឡុងពេលដាក់ពាក្យ (ក្នុងករណីនេះ ការវាយតម្លៃពីសាស្ត្រាចារ្យដឹកនាំ នឹងតម្រូវឱ្យមានជាចាំបាច់ក្នុងលិខិតណែនាំ)
- មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា។

## II. **មុខជំនាញទៅសិក្សា** (**សម្រាប់ទាំងពីរកម្រិត**)

១. Infrastructure Development

២. Private Sector Development

៣. Improvement of Education Quality

៤. Agriculture and Rural Development

៥. Improvement of Urban Living Environment

៦. Improvement of Healthcare and Social Security System

៧. Improvement of Administrative Functions

៨. Legal and Judicial Development

៩. Building of International Relations

## III. **កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ**

បេក្ខជនដែលមានបំណងដាក់ពាក្យកម្មវិធីអាហារូបករណ៍នេះ សូមបំពេញសំណុំឯកសារផ្សេងៗ និងផ្ញើមកកាន់ការិយាល័យ **JICE-JDS** ដែលមានអាសយដ្ឋាន៖ អគារ AURA Condominium ជាន់ទី៣ ផ្ទះលេខ៨៧ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ (វិថីព្រះត្រសក់ផ្អែម)ចាប់ពី**ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២** រហូតដល់**ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២** ត្រឹមម៉ោង **៣:០០ រសៀល**។

សេចក្ដីណែនាំអំពីការដាក់ពាក្យ និងពាក្យសុំអាហារូបករណ៍៖

- អាចទាញយកបានតាមគេហទំព័រ JDS៖ http://jds-scholarship.org/ (លេខសម្ងាត់ផ្ដល់ជូនតាមរយៈគេហទំព័រ JDS)
- បេក្ខជនត្រូវមានប័ណ្ណសំគាល់មន្ត្រីរាជការស៊ីវិល ឬលិខិតបញ្ជាក់ពីក្រសួងសាមុី
- បេក្ខជនដែលបំពេញការងារនៅតាមអង្គភាពគោលដៅ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចដាក់ពាក្យ ដោយជ្រើសរើសមុខវិជ្ជាសិក្សាណាមួយដែលសមស្រប(សូមមើលបញ្ជីមុខវិជ្ជាសិក្សា និងអង្គភាពគោលដៅ)
- បេក្ខជនត្រូវឆ្លងកាត់ការពិនិត្យជ្រើសរើសលើសំណុំឯកសារ និងការសម្ភាស។

## IV. សិក្ខាសាលាពន្យល់ណែនាំអំពីអាហារូបករណ៍ JDS

បេក្ខជនអាចស្វែងរកព័ត៌មានអំពីសិក្ខាសាលា និងការចុះឈ្មោះចូលរួមសិក្ខាសាលាទុកជាមុន នៅលើគេហទំព័រJDS។ ខាងក្រោមគឺជាមុខវិជ្ជាសិក្សា និងកាលវិភាគសិក្ខាសាលាស្តីអំពីអាហារូបករណ៍ JDS សម្រាប់ឆ្នាំ២០២២៖

<table>
<tr><th>Components</th><th>Seminar information (Tentative)</th></tr>
<tr><td>Infrastructure Development</td><td rowspan="9"><u>Promotion seminars</u><br>September 3 (Sat) 9:00 – Phnom Penh<br>September 10 (Sat) 9:00 – Online<br><u>Consultation seminars by JDS alumni by each field</u><br>September 12-30 – Online<br><u>Introductory seminars by universities</u><br>To be determined – Online<br>For those who have difficulty in participating the seminars, tutorial movies are also available on the website<br>(1) Application Guidelines / (2) How to prepare the application documents / (3) How to write a research plan / (4) Tips for the selection</td></tr>
<tr><td>Private Sector Development</td></tr>
<tr><td>Improvement of Education Quality</td></tr>
<tr><td>Agriculture and Rural Development</td></tr>
<tr><td>Improvement of Urban Living Environment</td></tr>
<tr><td>Improvement of Healthcare and Social Security System</td></tr>
<tr><td>Improvement of Administrative Functions</td></tr>
<tr><td>Legal and Judicial Development</td></tr>
<tr><td>Building of International Relations</td></tr>
</table>

សម្រាប់ព័ត៌មានបន្ថែម បេក្ខជនអាចទាក់ទងសួរនៅការិយាល័យ JICE-JDS តាមរយៈអាសយដ្ឋានខាងលើ ឬទូរស័ព្ទលេខ៖ **012 681 611/ 023 217 944** ឬ email: jds.cambodia1@jice.org ។ល.ស

ថ្ងៃ ៣កើត ១៣កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា
- ក្រសួងមុខងារសាធារណៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

**"ដើម្បីជ្រាបជាព័ត៌មាន"**

- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់អង្គភាពគោលដៅ ចំណុះទីស្តីការក្រសួង អយក.

**"ដើម្បីជួយផ្សព្វផ្សាយដល់បេក្ខជន"**

- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

**"ដើម្បីចុះផ្សាយក្នុងគេហទំព័ររបស់ក្រសួង អយក."**

- កាលប្បវត្តិ
- ឯកសារ៖ នាយកដ្ឋាន ទវអ.